**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**លេខ៖ បព ៣០/២០២៥ កបទ.សអ**

សេចក្តីប្រកាសព័ត៌មាន

# កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការដោះលែង និងធ្វើមាតុភូមិនិវត្តន៍របស់កងទ័ពកម្ពុជាទាំង១៨រូប

**សម្តេចធិបតីនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត** បានផ្តល់អាទិភាពខ្ពស់បំផុត លើការធានាឱ្យមានការដោះលែង និងធ្វើមាតុភូមិនិវត្តន៍ របស់កងទ័ពកម្ពុជាទាំង១៨រូប ដែលកងកម្លាំងថៃបានឃុំខ្លួនបន្ទាប់ពីបទឈប់បាញ់ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ ។ **សម្តេចធិបតី** បានណែនាំដោយផ្ទាល់ដល់ស្ថាប័នរបស់រាជរដ្ឋាភិបាល ក្នុងការរិះរកគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន តាមទ្វេភាគី តំបន់ និងអន្តរជាតិ ដើម្បីធានានូវការវិលត្រឡប់មកវិញយ៉ាងឆាប់រហ័សនៃកងទ័ពទាំងនោះ ដោយសង្កត់ធ្ងន់ថាសុខុមាលភាពរបស់កងទ័ពដែលត្រូវបានឃុំខ្លួន គឺជាបញ្ហានៃសេចក្តីថ្លៃថ្នូររបស់ជាតិ និងជាកង្វល់ផ្នែកមនុស្សធម៌ជាបន្ទាន់។ ការចូលរួមដោយផ្ទាល់របស់**សម្តេចធិបតី** ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់របស់កម្ពុជា ក្នុងការការពារប្រជាជនរបស់ខ្លួន រក្សាអធិបតេយ្យជាតិ និងដោះស្រាយបញ្ហាដោយសន្តិវិធីក្នុងស្មារតីភាពជាអ្នកជិតខាងល្អ និងការជឿទុកចិត្តគ្នាទៅវិញទៅមក។

ក្នុងការគាំទ្រដល់ការដឹកនាំរបស់សម្តេចធិបតីនាយករដ្ឋមន្ត្រី **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុវត្តគំនិតផ្តួចផ្តើមការទូតយ៉ាងខ្ជាប់ខ្ជួន ដោយលើកឡើងជានិច្ចនូវបញ្ហានេះ ជាមួយដៃគូទ្វេភាគី តំបន់ និងអន្តរជាតិសំខាន់ៗ ក៏ដូចជាជាមួយបណ្តាអង្គទូត នៅរាជធានីភ្នំពេញ និងឥស្សរជនបរទេស ដែលបានមកបំពេញទស្សនកិច្ចនៅកម្ពុជា រួមទាំងប្រេសិតពិសេសសម្រាប់កិច្ចសហប្រតិបត្តិការមេគង្គរបស់ជប៉ុន ដើម្បីអំពាវនាវឱ្យមានការដោះលែងកងទ័ពកម្ពុជាជាបន្ទាន់។ ក្រោមការណែនាំរបស់**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបង្កើនកិច្ចខិតខំប្រឹងប្រែងទាំងនេះ ដោយចេញកំណត់ទូតធ្វើបទបង្ហាញអំពីស្ថានការណ៍ដល់បណ្តាអង្គទូតបរទេស ចូលរួមជាមួយយន្តការអាស៊ាន និងរក្សាកិច្ចសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយបណ្តាប្រទេសជាមិត្ត និងអង្គការអន្តរជាតិនានា។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ បានគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការការពារសិទ្ធិរបស់ប្រជាជនខ្លួន ការលើកកម្ពស់ការកាត់បន្ថយភាពតានតឹង និងការគោរពគោលការណ៍មនុស្សធម៌អន្តរជាតិ។

ក្រសួងការពារជាតិបានសម្របសម្រួលយ៉ាងសកម្មជាមួយសមភាគីថៃ តាមរយៈយន្តការយោធាទ្វេភាគីដែលមានស្រាប់ ដើម្បីជំរុញឱ្យមានការវិលត្រឡប់ដោយសុវត្ថិភាពនៃកងទ័ពជាប់ឃុំ

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ: (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

ទាំង១៨រូប ស្របពេលជាមួយគ្នា ធានានូវការប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់ចំពោះបទឈប់បាញ់របស់ភាគីកម្ពុជា។ បន្ថែមលើនេះ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា បានចូលរួមជាមួយស្ថាប័នសិទ្ធិមនុស្សក្នុងតំបន់ និងអន្តរជាតិ ដើម្បីលើកឡើងពីទិដ្ឋភាពមនុស្សធម៌នៃសំណុំរឿងនេះ ដោយសង្កត់ធ្ងន់លើសិទ្ធិ និងសេចក្តីថ្លៃថ្នូរ របស់កងទ័ពទាំង១៨រូបនេះ ព្រមទាំងអំពាវនាវឱ្យមានការគោរពពេញលេញនៃច្បាប់មនុស្សធម៌ និងសិទ្ធិមនុស្សអន្តរជាតិ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ ជួយពង្រឹងវិធីសាស្ត្ររួមរបស់រាជរដ្ឋាភិបាល ក្នុងការធានានូវមាតុភូមិនិវត្តន៍របស់កងទ័ពទាំង១៨រូប តាមរយៈមធ្យោបាយច្បាប់មនុស្សធម៌ និងការទូត។

ស្ថានបេសកកម្មការទូតកម្ពុជានៅបរទេស ជាពិសេសស្ថានតំណាងអចិន្ត្រៃយ៍កម្ពុជាប្រចាំអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក និងទីក្រុងហ្សឺណែវ បានឈរនៅជួរមុខក្នុងការតស៊ូមតិអន្តរជាតិ។ នៅទីក្រុងញូវយ៉ក ស្ថានបេសកកម្មបានលើកបញ្ហានេះជាផ្លូវការនៅអង្គការសហប្រជាជាតិ និងដៃគូអាស៊ាន ដោយជំរុញឱ្យធ្វើមាតុភូមិនិវត្តន៍នៃកងទ័ពទាំងនោះ និងធានាថា បញ្ហានេះនៅតែស្ថិតក្នុងរបៀបវារៈអន្តរជាតិ។ នៅទីក្រុងហ្សឺណែវ ស្ថានបេសកកម្មបានកៀរគរយ៉ាងសកម្មនូវស្ថាប័នមនុស្សធម៌ និងសិទ្ធិមនុស្ស រួមមានគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ដើម្បីត្រួតពិនិត្យលក្ខខណ្ឌនៃការឃុំខ្លួន និងជំរុញឱ្យមានការគោរពអនុសញ្ញាហ្សឺណែវ។

កម្ពុជាទាក់ទងជាមួយគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ដោយភាពស្មោះត្រង់ ដើម្បីស្វែងរកការគាំពារផ្នែកមនុស្សធម៌ មិនមែនការប្រឈមផ្នែកនយោបាយនោះទេ។ អាទិភាពបន្ទាន់របស់កម្ពុជាគឺច្បាស់លាស់ណាស់៖ អ្នកទោសសង្គ្រាមត្រូវផ្តល់សិទ្ធិក្នុងការចូលជួប ត្រួតពិនិត្យ និងធ្វើមាតុភូមិនិវត្តន៍, ជនស៊ីវិលត្រូវបានការពារពីការផ្លាស់ទីដោយបង្ខំ ការរឹបអូសដីធ្លីដោយខុសច្បាប់ និងការធ្វើឃោឃូបនីយកម្មលើផ្ទះសម្បែងរបស់ពួកគេ, សកម្មភាពប្រយុទ្ធត្រូវអនុវត្តតាមច្បាប់អន្តរជាតិ ដោយត្រូវបញ្ឈប់ការវាយប្រហារដោយមិនរើសមុខ ការរក្សានូវសម្បត្តិបេតិកភណ្ឌវប្បធម៌ និងការហាមឃាត់ការប្រើអាវុធខុសច្បាប់។

គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ បានបញ្ជាក់ឡើងវិញ នូវការទទួលស្គាល់របស់ខ្លួនចំពោះកងទ័ពទាំង១៨រូបនោះ ថាជាអ្នកទោសសង្គ្រាម ព្រមទាំងបានអះអាងថា នឹងធ្វើដំណើរទស្សនកិច្ចតាមដាននៅដើមខែកញ្ញា ដើម្បីផ្ទៀងផ្ទាត់លក្ខខណ្ឌ និងធានានូវការទាក់ទងជាមួយក្រុមគ្រួសារ។ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ បានប្តេជ្ញាធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរកម្ពុជា ដើម្បីធ្វើការវាយតម្លៃនៅតាមទីកន្លែង ត្រួតពិនិត្យលក្ខខណ្ឌមនុស្សធម៌ និងដោះស្រាយរាល់បញ្ហាដែលពាក់ព័ន្ធនឹងជនភៀសសឹក និងលើកឡើងពីការប្រើប្រាស់អាវុធហាមឃាត់ ស្របតាមអាណត្តិអព្យាក្រឹតរបស់គណកម្មាធិការកាកបាទក្រហមអន្តរជាតិ។

ថ្ងៃអាទិត្យ ១៥កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៥

KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION

No. PR 30/2025 MFA.IC

PRESS RELEASE

## Endeavors of the Royal Government of Cambodia for the Release and Repatriation of 18 Detained Soldiers

Samdech Thipadei Prime Minister HUN Manet has placed the highest priority on securing the safe release and repatriation of the 18 Cambodian soldiers detained by Thai forces following the 28 July 2025 ceasefire. He has directly guided the Royal Government's institutions to pursue every possible channel—bilateral, regional, and international—to ensure their swift return, emphasizing that the welfare of the detained soldiers is a matter of national dignity and urgent humanitarian concern. His personal engagement reflects Cambodia's steadfast determination to protect its people, uphold national sovereignty, and resolve the issue peacefully in a spirit of good neighborliness and mutual trust.

In support of the Prime Minister's leadership, Deputy Prime Minister and Minister of Foreign Affairs and International Cooperation, H.E. PRAK Sokhonn, has undertaken sustained diplomatic initiatives, consistently raising the matter with key bilateral, regional, and international partners, as well as with the Diplomatic Corps in Phnom Penh and visiting foreign dignitaries, including Japan's Special Envoy for Mekong Cooperation, to advocate for the soldiers' immediate release. Acting under his instructions, the Ministry of Foreign Affairs and International Cooperation has intensified these efforts by issuing Note Verbales, organizing diplomatic briefings, engaging with ASEAN mechanisms, and maintaining close coordination with friendly countries and international organizations. These endeavors underscore Cambodia's commitment to defending the rights of its nationals, promoting de-escalation, and upholding international humanitarian principles.

Address : N° 3, Samdech HUN Sen Street,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Kingdom of Cambodia

Tel : (855) 23 216 122
Fax : (855) 23 216 141, 023 213 341
Email : mfaic@mfaic.gov.kh

The Ministry of National Defense has actively coordinated with its Thai counterpart through the existing bilateral military mechanisms to press for the safe return of the 18 detained soldiers, while simultaneously ensuring strict adherence to the ceasefire on Cambodia's side. Complementing this, the Cambodian Human Rights Committee has engaged with regional and international human rights bodies to highlight the humanitarian dimension of the case, emphasizing the rights and dignity of the detained soldiers and calling for full respect of international humanitarian and human rights law. Together, these efforts reinforce the Royal Government's unified approach to securing the soldiers' repatriation through legal, humanitarian, and diplomatic means.

The Cambodian Diplomatic Missions abroad, particularly the Permanent Missions to the United Nations in New York and Geneva, have been at the forefront of international advocacy. In New York, the Mission has formally raised the issue before the United Nations and ASEAN partners, urging the soldiers' repatriation and ensuring the matter remains on the international agenda. In Geneva, the Mission has actively mobilized humanitarian and human rights institutions, including the ICRC and OHCHR, to monitor detention conditions and press for compliance with the Geneva Conventions.

Cambodia approaches the ICRC in good faith—seeking humanitarian protection, not political confrontation. Its urgent priorities are clear: prisoners of war must be granted access, monitoring, and repatriation; civilians must be safeguarded from forced transfer, unlawful land seizures, and the militarization of their homes; and hostilities must be conducted in accordance with international law—ending indiscriminate attacks, preserving cultural heritage, and prohibiting outlawed weapons.

The ICRC reaffirmed its recognition of the 18 detained soldiers as prisoners of war and confirmed that follow-up visits would be conducted in early September to verify their conditions and ensure family contact. The ICRC committed to working closely with Cambodian authorities to conduct field assessments, monitor humanitarian conditions, and address concerns related to displaced civilians and the alleged use of prohibited weapons, in line with the ICRC's neutral mandate.

Phnom Penh, 7 September 2025